ក

មាតិកា

I-ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២២-៨-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៨០៧/៣៧៩ ស្តីពីការតែងតាំងឯកឧត្តម **យ៉ាន មុនម៉េង** ជាសមាជិកទី ១ នៃអាជ្ញាធរអគ្គិសនីកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ សម្រាប់អាណត្តិបន្តទៀត ៦៧៧១

២២-៨-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៨០៧/៣៨០ ស្តីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជាកិច្ចបច្ឆាមរណៈ ជូនចំពោះសពលោកវរសេនីយ៍ឯក **យ៉េន ថន** នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៦៧៧២

២២-៨-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៨០៧/៣៨១ ស្តីពីការបំពាក់គ្រឿងឥស្សរិយយស មេដាយការពារជាតិ តាមលំដាប់ថ្នាក់ ជូននាយនគរបាលជាតិជាន់ខ្ពស់ ថ្នាក់ឧត្តមសេនីយ៍ នៃក្រសួងមហាផ្ទៃចំនួន ៤៨រូប ដែលមានស្នាដៃក្នុងការបំរើជាតិមាតុភូមិ ៦៧៧៣

២៣-៨-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៨០៧/៣៨៣ ស្តីពីការកែសម្រួលភារកិច្ចឯកឧត្តម ឧត្តមសេនីយ៍ឯក **ម៉ា ឈឿន** ពីនាយកសាលាភូមិន្ទនគរបាល ទៅជាប្រធានបណ្ឌិតសភានគរបាលកម្ពុជា បន្ថែមលើតួនាទីបច្ចុប្បន្នជាប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ៦៧៧៥

២៣-៨-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៨០៧/៣៨៤ ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ០៧ រូប ៦៧៧៦

២៣-៨-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៨០៧/៣៨៥ ស្តីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម លោកជំទាវ លោកឧកញ៉ា និងអស់លោក ចំនួន ០៨ រូប ៦៧៧៧

II-រាជរដ្ឋាភិបាល

១-អនុក្រឹត្យ

២៤-៨-២០០៧ -អនុក្រឹត្យលេខ ១០៨ អនក្រ.បក ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ ៦៧៧៨

២១-៨-២០០៧ -អនុក្រឹត្យលេខ ៦៩៧ អនក្រ.តត ស្តីពីការតម្លើងថ្នាក់ និងឋានន្តរសក្តិមន្ត្រីរាជការ ៦៧៨៩

២២-៨-២០០៧ -អនុក្រឹត្យលេខ ៦៩៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦៧៩១

២២-៨-២០០៧ -អនុក្រឹត្យលេខ ៦៩៩ អនក្រ.តត ស្តីពីការកែសំរួលភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិ ៦៧៩២

២២-៨-២០០៧ -អនុក្រឹត្យលេខ ៧០០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦៧៩៤

២២-៨-២០០៧ -អនុក្រឹត្យលេខ ៧០១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៧៩៥

២២-៨-២០០៧ -អនុក្រឹត្យលេខ ៧០២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៧៩៦

២២-៨-២០០៧ -អនុក្រឹត្យលេខ ៧០៣ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា ៦៧៩៧

២២-៨-២០០៧ -អនុក្រឹត្យលេខ ៧០៤ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៦៧៩៨

២២-៨-២០០៧ -អនុក្រឹត្យលេខ ៧០៥ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៦៧៩៩

២_សេចក្តីសម្រេច

២៨-៨-២០០៧ -សេចក្តីសម្រេចលេខ ៤៥ សសរ ស្តីពីការកែសំរួលសេចក្តីសំរេច ស្តីពីការបង្កើតគណៈកម្មាធិការ អនុគណៈកម្មាធិការដឹកនាំការងារ ដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន និងក្រុមការងារតាមវិស័យសំរាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយផ្នែកឯកជន ៦៨០១

III_ការងារបណ្តាក្រសួង

១_ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាស

១២-៦-២០០៧ -ប្រកាសលេខ ៤៦៥ សហវ ស្តីពីការដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជាឆ្នាំ ២០០៧ *(ត មកពីរាជកិច្ច លេខ ៤៥...ដល់...៦៣)* ៦៨១០

២_ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

២០-៨-២០០៧ -ប្រកាសលេខ ៨៤៦ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ណានតាយ ហ្គាមេន ហ្វាក់ធើរី (ខេមបូឌា) លីមីធីត បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា " ណានតាយ ហ្គាមេន ហ្វាក់ធើរី (ខេមបូឌា) លីមីធីត " ៦៨៥៩

២០-៨-២០០៧ -ប្រកាសលេខ ៨៤៧ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ខេ-សំ ចិចថាយ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់-កម្រាលគុ-ស្រោមពូក និងកន្សែង" ដែលមានឈ្មោះថា " ខេ-សំ ចិចថាយ " ៦៨៦១

២០-៨-២០០៧	-ប្រកាសលេខ ៨៤៨ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន វីង យីង (ខេមបូឌា) ហ្គាមេន ហ្វាក់ធើរី អិលធីឌី បង្កើតរោងចក្រ "កាត់ដេរ និងចាក់សម្លៀកបំពាក់ " ដែលមានឈ្មោះថា " វីង យីង (ខេមបូឌា) ហ្គាមេន ហ្វាក់ធើរី អិលធីឌី "	៦៨៦៣
២០-៨-២០០៧	-ប្រកាសលេខ ៨៤៩ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ឃុយ ភាព ហ្គាមេន បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់ " ដែលមានឈ្មោះថា " ឃុយ ភាព ហ្គាមេន "	៦៨៦៥

៣_ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០២-៣-២០០៧	-លិខិតបញ្ជាក់លេខ ០៩៣៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សម្បត្តិ រាសី**	៦៨៦៧
០២-៣-២០០៧	-លិខិតបញ្ជាក់លេខ ០៩៣៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **(ខេមបូឌា) សាន់នី ម្រ៉ីន ឆែន**	៦៨៦៩
០២-៣-២០០៧	-លិខិតបញ្ជាក់លេខ ០៩៣៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឡឹម ត្រីអេឆ**	៦៨៧១
០២-៣-២០០៧	-លិខិតបញ្ជាក់លេខ ០៩៣៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សណ្ឋាគារ ឡាក់ស្ទឺរី ទើលដ៍**	៦៨៧៣
០២-៣-២០០៧	-លិខិតបញ្ជាក់លេខ ០៩៣៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស ទី ឌី ខូ អិលធីឌី**	៦៨៧៥
០២-៣-២០០៧	-លិខិតបញ្ជាក់លេខ ០៩៤០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិម អ ឌី ស៊ី ខូ អិលធីឌី**	៦៨៧៧
០២-៣-២០០៧	-លិខិតបញ្ជាក់លេខ ០៩៤១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខ្មែរ ៤៤០ អិលធីឌី**	៦៨៧៩
០២-៣-២០០៧	-លិខិតបញ្ជាក់លេខ ០៩៤៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិល ឌី ទី អ៊ិនធើណេសិនណល**	៦៨៨១

ព្រះរាជក្រឹត្យ

នស/រកត/០៨០៧/៣៧៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៥ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ៩ នៃច្បាប់ស្តីពីអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំងឯកឧត្តម យ៉ាវ ម៉ុនម៉េង ជាសមាជិកទី១ នៃអាជ្ញាធរអគ្គិសនីកម្ពុជា មានឋានៈស្មើអនុរដ្ឋលេខាធិការ សម្រាប់អាណត្តិបន្តទៀត។

មាត្រា២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៤ល.០៧០៨.៤០៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៧

លេខ:៣៧៧៦.ណ
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ ៨ ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃួន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៨០៧/៣៨០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជាកិច្ចបច្ឆាមរណៈជូនចំពោះសពលោកវរសេនីយ៍ឯក **ឃិន ខន** អត្តលេខ ០២២៤ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៧៧.០៧០៩.៤០៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៧

លេខ: ៣៨៦ ក.ច

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ២០០៧

[illegible] ជិនកេន

នស/រកត/០៨០៧/៣៨១

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : បំពាក់គ្រឿងឥស្សរិយយស **មេដាយការពារជាតិ** តាមលំដាប់ថ្នាក់ ជូននាយនគរបាលជាតិជាន់ខ្ពស់ ថ្នាក់ឧត្តមសេនីយ៍ នៃក្រសួងមហាផ្ទៃ ចំនួន ៤៨ រូប ដែលមានស្នាដៃក្នុងការបំរើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :

ក - ***មេដាយការពារជាតិ** ថ្នាក់មាស ០២ គ្រឿង ប្រាក់ ០២ គ្រឿង សំរិទ្ធ ០២ គ្រឿង ចំនួន ០២ រូប :*

១ លោកឧត្តមសេនីយ៍ត្រី រុន រ័ត្នវាសនា
២ លោកឧត្តមសេនីយ៍ត្រី ជា សុមេធី

ខ - ***មេដាយការពារជាតិ** ថ្នាក់មាស ០១ គ្រឿង ប្រាក់ ០១ គ្រឿង សំរិទ្ធ ០១ គ្រឿង ចំនួន ៤៦ រូប :*

១	លោកឧត្តមសេនីយ៍ត្រី	ថាំ	សាន្ត	៣	លោកឧត្តមសេនីយ៍ត្រី	ឃុន	សំបូរ
២	លោកឧត្តមសេនីយ៍ត្រី	សំ	បូរ	៤	លោកឧត្តមសេនីយ៍ត្រី	ខេង	លីដា

៥	លោកឧត្តមសេនីយ៍ត្រី	ច័ន្ទ	សុវណ្ណ	២៦	លោកឧត្តមសេនីយ៍ត្រី	សារ៉ាយ	ឆុន
៦	លោកឧត្តមសេនីយ៍ត្រី	មីក់	ជីតូ	២៧	លោកឧត្តមសេនីយ៍ត្រី	សុខ	ច័ន្ទរិទ្ធី
៧	លោកឧត្តមសេនីយ៍ត្រី	ផូ	ខន	២៨	លោកឧត្តមសេនីយ៍ត្រី	ណុប	រី
៨	លោកឧត្តមសេនីយ៍ត្រី	ម៉ាត់	ណូរី	២៩	លោកឧត្តមសេនីយ៍ត្រី	សេង	វណ្ណា
៩	លោកឧត្តមសេនីយ៍ត្រី	តាន់	ចាយ	៣០	លោកឧត្តមសេនីយ៍ត្រី	ញាណ	វិបុល
១០	លោកឧត្តមសេនីយ៍ត្រី	ហ៊ូ	សាគុណ	៣១	លោកឧត្តមសេនីយ៍ត្រី	ព្រុំ	ធា
១១	លោកឧត្តមសេនីយ៍ត្រី	ជា	ណារ៉េត	៣២	លោកឧត្តមសេនីយ៍ត្រី	ជោត	សំរាំង
១២	លោកឧត្តមសេនីយ៍ត្រី	ចាន់	គីមសេង	៣៣	លោកឧត្តមសេនីយ៍ត្រី	សោម	សុភាព
១៣	លោកឧត្តមសេនីយ៍ត្រី	រស់	សារិទ្ធ	៣៤	លោកឧត្តមសេនីយ៍ត្រី	ហ៊ុម	ផុន
១៤	លោកឧត្តមសេនីយ៍ត្រី	ភន	បូរ៉ាមី	៣៥	លោកឧត្តមសេនីយ៍ត្រី	យ៉េត	រ៉ាហ្សាក់
១៥	លោកឧត្តមសេនីយ៍ត្រី	អៀង	សាមីន	៣៦	លោកឧត្តមសេនីយ៍ត្រី	ខឹម	កាន
១៦	លោកឧត្តមសេនីយ៍ត្រី	ស៊ូ	បាន	៣៧	លោកឧត្តមសេនីយ៍ត្រី	ឆាយ	គីមខឿន
១៧	លោកឧត្តមសេនីយ៍ត្រី	សោម	ឡាញ់	៣៨	លោកឧត្តមសេនីយ៍ត្រី	គីម	សាម៉ន
១៨	លោកឧត្តមសេនីយ៍ត្រី	ជិន	ចាយ	៣៩	លោកឧត្តមសេនីយ៍ត្រី	សុត	ផុល
១៩	លោកឧត្តមសេនីយ៍ត្រី	តង់	សារ៉ាន់	៤០	លោកឧត្តមសេនីយ៍ត្រី	ហួរ	ឡាមុន្នី
២០	លោកឧត្តមសេនីយ៍ត្រី	អៀក	ខែម	៤១	លោកឧត្តមសេនីយ៍ត្រី	ជា	សុគន្ធា
២១	លោកឧត្តមសេនីយ៍ត្រី	បូរីសាន	ជីឡូប៉េស	៤២	លោកឧត្តមសេនីយ៍ត្រី	អ៊ិន	ប៊ូរ៉ា
២២	លោកឧត្តមសេនីយ៍ត្រី	គុល	គីមលី	៤៣	លោកឧត្តមសេនីយ៍ត្រី	នៅ	លក្ខិណា
២៣	លោកឧត្តមសេនីយ៍ត្រី	ហ៊ូ	សេងលន់	៤៤	លោកឧត្តមសេនីយ៍ត្រី	ទូច	ណារ៉ុថ
២៤	លោកឧត្តមសេនីយ៍ត្រី	ថោង	សំអាត	៤៥	លោកឧត្តមសេនីយ៍ត្រី	សត	ណាឌី
២៥	លោកឧត្តមសេនីយ៍ត្រី	ថោង	វរលក្ខណ៍	៤៦	លោកឧត្តមសេនីយ៍ត្រី	ឌួន	សាមិន

មាត្រា ២: សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រ.០៧០៨.៤០៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៧

លេខ: ៣៩៥ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០០៧

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៨០៧/៣៨៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានកែសំរួលភារកិច្ចឯកឧត្តមឧត្តមសេនីយ៍ឯក ម៉ៅ សឿន អត្តលេខ ០០៨៨ ពីនាយកសាលាភូមិន្ទនគរបាល ទៅជាប្រធានបណ្ឌិតសភានគរបាលកម្ពុជា បន្ថែមលើតួនាទីបច្ចុប្បន្នជាប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខា នេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៧.០៧០៨.៤០៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៧

លេខ: ៣៨២៣.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ... ខែ ... ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៨០៧/៣៨៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋារាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

ក- ថ្នាក់ ឧត្តមសេនីយ៍ទោ :

១- លោកឧត្តមសេនីយ៍ត្រី សុខ ច័ន្ទរិទ្ធី អត្តលេខ ០៥៩២

ខ- ថ្នាក់ ឧត្តមសេនីយ៍ត្រី :

១- លោកវរសេនីយ៍ឯក សៅ ចិរៈឧទ័យ អត្តលេខ ០៥១៨
២- លោកវរសេនីយ៍ឯក ឌិត សារ៉ាត់ អត្តលេខ ០៨២២
៣- លោកវរសេនីយ៍ឯក ឆេព ធុន្នី អត្តលេខ ២៣០០
៤- លោកវរសេនីយ៍ឯក ស្វាយ ចាន់ដា អត្តលេខ ៣៤៦០
៥- លោកវរសេនីយ៍ឯក ឈួន សុផេង អត្តលេខ ៧៤៧៩
៦- លោកវរសេនីយ៍ឯក ភួន សុផល អត្តលេខ ៥៤៦៧៦

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៧០៨.៤០៨

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៧

លេខ: ៣៨១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចាន់ថុល

ព្រះរាជក្រឹត្យ

នស/រកត/០៨០៧/៣៨៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ក- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

១- ឯកឧត្តម ចម ប្រសិទ្ធ
២- ឯកឧត្តម តាង សេងហួរ
៣- ឯកឧត្តម ឡាង ម៉េងឃីន
៤- លោកជំទាវ យស់ ស៊ីមន
៥- ឧកញ៉ា សំ អាង
៦- លោកជំទាវ ស៊ុយ សុផាន

ខ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ :

១- ឧកញ៉ា សាង ឃួន
២- លោក សាង ម៉េង

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៧.០៧០៨.៤០៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៧

លេខ: ៣៨៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ចិនកេន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ...១០៨...អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យ សត្វ សាច់ និង ផលិតផលសត្វ

* * * * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៦០០ / ០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និង សេវា
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៣ ស្តីពី ការត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៥ ស្តីពី ការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង មជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៧

សម្រេច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះ កំណត់ការគ្រប់គ្រងសត្តឃាតដ្ឋាន សកម្មភាពអាជីវកម្មពិឃាតសត្វ ការត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ នៅតាមសត្តឃាតដ្ឋាន និង កន្លែងតាំងលក់ ក្នុងគោលបំណង ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺសត្វ ការពារសុខភាពសត្វ ធានាគុណភាពផលិតផល និង ការពារសុខភាពសាធារណៈ ក្នុងព្រះរាជាណាចក្រកម្ពុជា។

មិនអនុញ្ញាតឱ្យមានការពិឃាតសត្វយកសាច់ នៅរៀងរាល់ថ្ងៃឧបោសថសីល នៅតាមសត្តឃាតដ្ឋានទាំងអស់ ដោយយោងតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាបានកំណត់ថាព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ។

មាត្រា ២.-

ការគ្រប់គ្រងសត្តឃាតដ្ឋាន សកម្មភាពអាជីវកម្មពិឃាតសត្វ ការត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ ត្រូវស្ថិតក្រោមដែនសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

មាត្រា ៣.-

ពាក្យបច្ចេកទេសដែលប្រើប្រាស់សម្រាប់អនុក្រឹត្យនេះមានដូចខាងក្រោម÷

- **កន្លែងតាំងលក់:** សំដៅដល់កន្លែងដាក់លក់សាច់ និង ផលិតផលសត្វ នៅគ្រប់ទីកន្លែង
- **កន្លែងបង្ខាំងសត្វ:** សំដៅដល់កន្លែងរក្សាទុកសត្វ រយៈពេលពី ១២ (ដប់ពីរ) ទៅ ២៤ (ម្ភៃបួន) ម៉ោង ដើម្បីឱ្យសត្វសម្រាក និង ធ្វើការត្រួតពិនិត្យសុខភាពមុនពិឃាត ដោយភ្នាក់ងារបសុពេទ្យ
- **ត្រាបសុពេទ្យ:** សំដៅដល់ប្រដាប់ មានស្លាកចម្លាក់ជាគ្រឿងសម្គាល់ របស់អង្គភាពផលិតកម្ម និង បសុព្យាបាលមានសមត្ថកិច្ច សម្រាប់បោះ ឬ អូសលើផ្ទាំងសាច់ ក្រោយពេលត្រួតពិនិត្យអនាម័យសាច់ ដែលបញ្ជាក់ថា ផលិតផលនោះមានអនាម័យ គ្មានមេរោគបង្កជំងឺ និង មិនប៉ះពាល់សុខភាពសាធារណៈ
- **ផលិតផលសត្វ:** សំដៅដល់ឈាម គ្រឿងក្នុង ឆ្អឹង រោម ស្បែក ស្លាប ស្នែង ក្រចក លាមក ទឹកនោម និង កាកសំណល់ផ្សេងៗទៀត របស់សត្វដែលបានពិឃាត
- **ភ្នាក់ងារបសុពេទ្យ:** សំដៅដល់មន្ត្រីបសុពេទ្យ ដែលត្រូវបានចាត់តាំងឱ្យទទួលខុសត្រូវត្រួតពិនិត្យអនាម័យ សត្តឃាតដ្ឋាន អនាម័យសត្វ សាច់ និង ផលិតផលសត្វ នៅតាមសត្តឃាតដ្ឋាន និង កន្លែងតាំងលក់

- **ភិនសត្វ:** សំដៅដល់ប័ណ្ណចេញដោយអង្គភាពផលិតកម្ម និង បសុព្យាបាលមានសមត្ថកិច្ច ដើម្បី សម្គាល់ភិនភាគសត្វចតុប្បាទ ដោយបញ្ជាក់ពីប្រភេទសត្វ ភេទ អាយុ សម្បុរ ពូជ កម្ពស់ ស្នែង ក្រយៅ និង ស្លាកស្នាមផ្សេងៗ
- **វិញ្ញាបនបត្រអនាម័យសត្វ:** សំដៅដល់លិខិតចេញដោយសមត្ថកិច្ចផលិតកម្ម និង បសុព្យាបាល ពីប្រភព ដើមដែលសត្វនោះរស់នៅ ដើម្បីដឹកជញ្ជូនមកសត្តឃាតដ្ឋាន ។ វិញ្ញាបនបត្រនេះផ្តល់ឱ្យបន្ទាប់ពីបាន ធ្វើការត្រួតពិនិត្យសត្វ តាមលក្ខណៈបច្ចេកទេសបសុពេទ្យ ឃើញថាមានសុខភាពល្អ និង គ្មានមេរោគបង្ក ជំងឺឆ្លង
- **វិញ្ញាបនបត្របញ្ជាក់អនាម័យសាច់ និង ផលិតផលសត្វ :** សំដៅដល់លិខិត ដែលចេញដោយភ្នាក់ងារ បសុពេទ្យប្រចាំនៅសត្តឃាតដ្ឋាន ក្រោយពីបានធ្វើការត្រួតពិនិត្យ ឬ វិភាគលើសាច់ និង ផលិតផលសត្វ ឃើញថា មានគុណភាពល្អ គ្មានមេរោគបង្កជំងឺឆ្លងសត្វ និង មិនប៉ះពាល់ដល់សុខភាពសាធារណៈ តាម លក្ខណៈបច្ចេកទេសបសុពេទ្យ
- **វិធានបសុពេទ្យ:** សំដៅដល់ការធ្វើអនាម័យសត្តឃាតដ្ឋាន ការសម្លាប់មេរោគ ធ្វើអនាម័យ ការរំលុត បញ្ចេញចោល កាត់ផ្តាច់មិនឱ្យឆ្លងបាន សម្លាប់ចោល កប់ ឃាត់ទុក បង្វែរទិសដៅប្រើប្រាស់ ឬ ដុត បំផ្លាញចោល សត្វ សាច់ និង ផលិតផលសត្វ ដែលគ្មានអនាម័យ ផ្ទុកមេរោគ ឬ មានជំងឺ
- **សាច់:** សំដៅដល់ផ្នែកទាំងអស់នៃសត្វ ដែលអាចបរិភោគបាន លើកលែងតែផលិតផលសត្វ ដែលមាន ចែងក្នុងអនុក្រឹត្យនេះ
- **សាច់ ផលិតផលសត្វមានរោគ :** សំដៅដល់សាច់ និង ផលិតផលសត្វ ដែលផ្ទុកទៅដោយមេរោគដូចជាៈ វីរុស បាក់តេរី ប៉ារ៉ាស៊ីត ផ្សិត និង ប្រភេទអតិសុខុមប្រាណផ្សេងៗទៀត
- **សត្តឃាតដ្ឋាន:** សំដៅដល់កន្លែងប្រមូលផ្តុំសម្លាប់សត្វជាប្រចាំ ដើម្បីយកសាច់ធ្វើអាជីវកម្ម ឬម្ហូបអាហារ ដោយធានាគុណភាពអនាម័យ
- **កម្រៃត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ:** សំដៅដល់ចំនួនទឹកប្រាក់ ដែលអាជីវករត្រូវ បង់កម្រៃ លើការបម្រើសេវាកម្មត្រួតពិនិត្យ សត្វ សាច់ និង ផលិតផលសត្វ
- **សត្វផ្ទុកមេរោគ:** សំដៅដល់សត្វដែលមានផ្ទុកមេរោគ ដោយពុំទាន់បង្ហាញរោគសញ្ញា ប៉ុន្តែអាចពិនិត្យ ឃើញតាមរយៈការវិភាគនៅមន្ទីរពិសោធន៍
- **សត្វមានជំងឺ:** សំដៅដល់សត្វដែលបានបង្ហាញរោគសញ្ញាច្បាស់លាស់ ។ រោគសញ្ញាអាចពិនិត្យឃើញ ដោយផ្ទាល់ ឬ តាមការវិភាគនៅមន្ទីរពិសោធន៍

- **សំណាកសម្រាប់ធ្វើវិភាគ:** សំដៅដល់ផ្នែកមួយរបស់សត្វ សាច់ ឬ ផលិតផលសត្វ ដែលត្រូវបានយកសម្រាប់ពិនិត្យ និង វិភាគនៅមន្ទីរពិសោធន៍
- **ស្លាកបសុពេទ្យ:** សំដៅដល់ស្លាក ឬ តែមប្រើបសុពេទ្យរបស់អង្គភាពផលិតកម្ម និង បសុព្យាបាល បិទសម្គាល់លើកញ្ចប់សាច់ និង ផលិតផលសត្វក្រោយពេលត្រួតពិនិត្យដែលបញ្ជាក់ថា មានអនាម័យ គ្មានមេរោគបង្កជំងឺ និង មិនប៉ះពាល់សុខភាពសាធារណៈ
- **អត្តសញ្ញាណប័ណ្ណសត្វ:** សំដៅដល់ប័ណ្ណចេញដោយអង្គភាពផលិតកម្ម និង បសុព្យាបាលមានសមត្ថកិច្ច ដើម្បីសម្គាល់លក្ខណៈសត្វចតុប្បាទ ធំ តូច និង បក្សី
- **អាជីវកម្មពិឃាតសត្វ:** សំដៅដល់ការពិឃាតសត្វយកសាច់ និង ផលិតផលសត្វសម្រាប់ធ្វើពាណិជ្ជកម្ម ។

ជំពូកទី ២
ការគ្រប់គ្រងសត្តឃាតដ្ឋាន និង ការធ្វើអាជីវកម្មពិឃាតសត្វ

មាត្រា ៤.-

សត្តឃាតដ្ឋានត្រូវបានធ្វើការបែងចែកដូចតទៅ៖

៤.១ សត្តឃាតដ្ឋានគោ-ក្របី:

- ប្រភេទ "ក" ពិឃាតចាប់ពី ៥០ (ហាសិប) ក្បាលឡើងទៅ ក្នុងរយៈពេល២៤ (ម្ភៃបួន) ម៉ោង
- ប្រភេទ "ខ" ពិឃាតតិចជាង ៥០ (ហាសិប) ក្បាល ក្នុងរយៈពេល ២៤ (ម្ភៃបួន) ម៉ោង ។

៤.២ សត្តឃាតដ្ឋានជ្រូក:

- ប្រភេទ "ក" ពិឃាតចាប់ពី ១០០ (មួយរយ) ក្បាលឡើងទៅ ក្នុងរយៈពេល២៤ (ម្ភៃបួន) ម៉ោង
- ប្រភេទ "ខ" ពិឃាតតិចជាង ១០០ (មួយរយ) ក្បាល ក្នុងរយៈពេល ២៤ (ម្ភៃបួន) ម៉ោង ។

៤.៣ សត្តឃាតដ្ឋានបក្សី:

- ប្រភេទ "ក" ពិឃាតចាប់ពី ៥០០០ (ប្រាំពាន់) ក្បាលឡើងទៅ ក្នុងរយៈពេល២៤ (ម្ភៃបួន) ម៉ោង
- ប្រភេទ "ខ" ពិឃាតតិចជាង ៥០០០ (ប្រាំពាន់) ក្បាល ក្នុងរយៈពេល ២៤ (ម្ភៃបួន) ម៉ោង ។

ប្រភេទសត្តឃាតដ្ឋានដទៃទៀត ដែលមិនបានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

មាត្រា ៥.-

សត្តឃាតដ្ឋាន ត្រូវមានទីតាំងនៅកន្លែងសមស្រប និង ត្រូវសាងសង់តាមបទដ្ឋានបច្ចេកទេស ដើម្បីធានាអនុវត្តវិធានបសុពេទ្យ អនាម័យ និង លក្ខខណ្ឌបច្ចេកទេសគ្រប់គ្រាន់សម្រាប់ការពិឃាតសត្វ ពិនិត្យសាច់ និង ផលិតផលសត្វ ។

ទីតាំង និង បទដ្ឋានបច្ចេកទេសសម្រាប់ការសាងសង់សត្តឃាតដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

មាត្រា ៦.-

ការបង្កើតសត្តឃាតដ្ឋាន និង ការធ្វើអាជីវកម្មពិឃាតសត្វគ្រប់ប្រភេទ ត្រូវមានលិខិតអនុញ្ញាតចេញដោយសមត្ថកិច្ចផលិតកម្ម និង បសុព្យាបាល ។

ចំពោះទីតាំងសម្រាប់ការសាងសង់សត្តឃាតដ្ឋានគ្រប់ប្រភេទ ត្រូវចុះទិដ្ឋាការពីអាជ្ញាធរ ខេត្ត ក្រុងសាមី ។

លិខិតអនុញ្ញាតបង្កើតសត្តឃាតដ្ឋានត្រូវបានផ្តល់ដោយ:

ក- នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ដោយមានការឯកភាពជាគោលការណ៍ ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ចំពោះសត្តឃាតដ្ឋានក្នុងប្រភេទ " ក " ។

ខ- មន្ទីរកសិកម្ម តាមសំណើរបស់ការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្ត ក្រុងសាមី ចំពោះសត្តឃាតដ្ឋានក្នុងប្រភេទ " ខ " ដោយមានការឯកភាពជាគោលការណ៍ផ្នែកបច្ចេកទេស ពីនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ។

លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មពិឃាតសត្វគ្រប់ប្រភេទ ត្រូវបានផ្តល់ដោយ:

ក- នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល តាមសំណើរបស់ការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្ត ក្រុងសាមី ចំពោះការធ្វើអាជីវកម្មពិឃាតសត្វ ក្នុងសត្តឃាតដ្ឋានប្រភេទ " ក " ។

ខ- ការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្ត ក្រុង ដោយមានទិដ្ឋាការពីមន្ទីរកសិកម្មខេត្ត ក្រុងនោះ ចំពោះការធ្វើអាជីវកម្មពិឃាតសត្វ ក្នុងសត្តឃាតដ្ឋានប្រភេទ " ខ " ។

គំរូលិខិតអនុញ្ញាត ទម្រង់ បែបបទសុំបង្កើតសត្តឃាតដ្ឋាន ការធ្វើអាជីវកម្មពិឃាតសត្វ និង បទបញ្ជាផ្ទៃក្នុងរបស់សត្តឃាតដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

មាត្រា ៧.-

រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបានទទួលការអនុញ្ញាតឱ្យធ្វើអាជីវកម្មពិឃាតសត្វ មានកាតព្វកិច្ចដូចតទៅ÷

ក- ត្រូវប្រគល់ដល់ភ្នាក់ងារបសុពេទ្យនូវលិខិតដឹកជញ្ជូនសត្វ វិញ្ញាបនបត្រអនាម័យសត្វ អត្តសញ្ញាណប័ណ្ណសត្វ ឬ ភិនសត្វ។

ខ- រក្សាទុកសត្វនៅកន្លែងបង្ខាំងសត្វ ក្នុងសត្តឃាតដ្ឋាន រយៈពេលពី១២ (ដប់ពីរ) ទៅ២៤ (ម្ភៃបួន) ម៉ោង មុនធ្វើការពិឃាត ដើម្បីឱ្យភ្នាក់ងារបសុពេទ្យត្រួតពិនិត្យសុខភាព។

គ- បង្កភាពងាយស្រួលដល់ភ្នាក់ងារបសុពេទ្យត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋាន សត្វ សាច់ និង ផលិតផលសត្វ ឬ យកសំណាកសម្រាប់ធ្វើវិភាគ។

ឃ-បង់កម្រៃសេវាកម្មត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ ស្របតាមមាត្រា ១៦ នៃអនុក្រឹត្យនេះ។

ង- ត្រូវអនុវត្តតាមបែបបទ និង បទបញ្ជាបសុពេទ្យ នៅពេលដឹកជញ្ជូនសាច់ និង ផលិតផលសត្វចេញពីសត្តឃាតដ្ឋាន ។ បែបបទ និង បទបញ្ជាបសុពេទ្យនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

មាត្រា ៨.-

ការធ្វើអាជីវកម្មពិឃាតសត្វ ត្រូវធ្វើនៅក្នុងសត្តឃាតដ្ឋាន ។ ការពិឃាតសត្វសម្រាប់ការពិសោធន៍ស្រាវជ្រាវ អាចធ្វើនៅក្រៅសត្តឃាតដ្ឋានបាន ដោយមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

មាត្រា ៩.-

ការធ្វើអាជីវកម្មពិឃាតសត្វ ត្រូវមានការអនុញ្ញាត ពីសមត្ថកិច្ចផលិតកម្ម និង បសុព្យាបាល។

ការធ្វើអាជីវកម្មលក់សាច់ និង ផលិតផលសត្វ ត្រូវបោះត្រា អូសត្រា ឬ បិទស្លាកសម្គាល់ និង មានលិខិតបញ្ជាក់អនាម័យពីអង្គភាពផលិតកម្ម និង បសុព្យាបាល។

ការលក់សាច់ និង ផលិតផលសត្វ ដែលមានប្រភពមេរោគបង្កជំងឺឆ្លងរាតត្បាត ឬ មានមេរោគបង្កជំងឺឆ្លងរាតត្បាតដល់សត្វ ឬ មនុស្ស ត្រូវហាមឃាត់។

ការក្លែងបន្លំត្រា ឬ ស្លាកសញ្ញារបស់អង្គភាពផលិតកម្ម និង បសុព្យាបាល សម្រាប់សម្គាល់ការត្រួតពិនិត្យអនាម័យសាច់ និង ផលិតផលសត្វ ត្រូវហាមឃាត់។

ជំពូកទី ៣

សមត្ថកិច្ចត្រួតពិនិត្យ អនាម័យសត្តឃាតដ្ឋាន អនាម័យសត្វ សាច់ និង ផលិតផលសត្វ នៅតាមសត្តឃាតដ្ឋាន និង កន្លែងតាំងលក់

មាត្រា ១០.-

ការត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋាន អនាម័យសត្វ សាច់ និង ផលិតផលសត្វ នៅតាមសត្តឃាតដ្ឋាន ដូចមានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ និង ការត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ នៅតាមកន្លែងតាំងលក់ ត្រូវស្ថិតក្នុងដែនសមត្ថកិច្ចរបស់ការិយាល័យផលិតកម្ម និង បសុព្យាបាលនៃមន្ទីរកសិកម្ម ខេត្ត ក្រុង ដោយសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ។

ក្នុងករណីចាំបាច់ នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល មានសមត្ថកិច្ចចុះត្រួតពិនិត្យការងារសត្តឃាតដ្ឋាន អនាម័យសត្វ សាច់ និង ផលិតផលសត្វ តាមកន្លែងតាំងលក់នៅទូទាំងប្រទេស ដោយសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ។ ការចុះត្រួតពិនិត្យនេះ ត្រូវធ្វើជាលក្ខណៈរួមក្នុងពេលតែមួយលើក។

នីតិវិធីនៃការត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋាន អនាម័យសត្វ សាច់ និង ផលិតផលសត្វ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

មាត្រា ១១.-

ភ្នាក់ងារបសុពេទ្យមានសមត្ថកិច្ចត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ នៅតាមសត្តឃាតដ្ឋាន និង នៅតាមកន្លែងតាំងលក់ មានភារកិច្ចដូចតទៅ÷

ក. ភ្នាក់ងារបសុពេទ្យមានសមត្ថកិច្ចនៅតាមសត្តឃាតដ្ឋាន

- ពិនិត្យអនាម័យសត្តឃាតដ្ឋាន
- ពិនិត្យលិខិតស្នាមដូចមានចែងក្នុងមាត្រា ៧ ចំណុច ក ពិនិត្យសត្វរស់មុនពិឃាត និង បង់លេខសម្គាល់សត្វ
- ពិនិត្យអនាម័យ កំណត់គុណភាពសាច់សត្វពិឃាតហើយ និង ផលិតផលសត្វ
- បោះ ឬ អូសត្រាលើផ្ទាំងសាច់ ឬ បិទស្លាកបសុពេទ្យលើកញ្ចប់សាច់ និង ផលិតផលសត្វ និង ចេញវិញ្ញាបនបត្របញ្ជាក់អនាម័យ
- ចាត់វិធានការបសុពេទ្យ ចំពោះការអនុវត្តផ្ទុយពីលក្ខខណ្ឌបច្ចេកទេស និង បទប្បញ្ញត្តិបសុពេទ្យ
- កត់ត្រាសត្វមុន និង ក្រោយពិឃាត បរិមាណសាច់ និង ផលិតផលសត្វ

ខ. ភ្នាក់ងារបសុពេទ្យមានសមត្ថកិច្ចនៅតាមកន្លែងតាំងលក់

- ពិនិត្យវិញ្ញាបនបត្របញ្ជាក់អនាម័យសាច់ និង ផលិតផលសត្វ
- ពិនិត្យអនាម័យ គុណភាពសាច់ និង ផលិតផលសត្វ
- ពិនិត្យអនាម័យកន្លែងតាំងលក់សាច់ និង ផលិតផលសត្វ
- ចាត់វិធានការបសុពេទ្យ ចំពោះការអនុវត្តផ្ទុយពីលក្ខខណ្ឌបច្ចេកទេស និង បទប្បញ្ញត្តិបសុពេទ្យ

ប្រភេទត្រា ឬ ស្លាកបសុពេទ្យសម្រាប់សម្គាល់ការត្រួតពិនិត្យអនាម័យសាច់ និង ផលិតផលសត្វនេះត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

មាត្រា ១២.-

ស្ថិតក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន ដូចមានចែងក្នុងមាត្រា ៦ និង ១០ នៃអនុក្រឹត្យនេះ អង្គភាពផលិតកម្ម និង បសុព្យាបាលមានសិទ្ធិ៖

- ណែនាំ ឬ ព្រមានជាលាយល័ក្ខណ៍អក្សរ
- ឃាត់ទុកនូវសត្វ សាច់ និង ផលិតផលសត្វ ដើម្បីអនុវត្តវិធានបសុពេទ្យ
- បង្វែរទិសដៅប្រើប្រាស់ ឬ កម្ទេចចោលសាច់ និង ផលិតផលសត្វ ខ្វះគុណភាព ឬ ខ្វះអនាម័យ ។ ការបង្វែរទិសដៅ និង ការកម្ទេចចោល អាចចាត់ចែងបានដោយភ្នាក់ងារបសុពេទ្យ លុះត្រាតែមានការអនុញ្ញាតពីស្ថាប័នរបស់ខ្លួន និង ការយល់ព្រមពីព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង
- បញ្ឈប់ជាបណ្តោះអាសន្ន ឬ ជាស្ថាពរ នូវសត្តឃាតដ្ឋាន និង ការធ្វើអាជីវកម្មពិឃាតសត្វ ។

ក្នុងករណីមានបទល្មើស ត្រូវធ្វើកំណត់ហេតុ និង ចងក្រងសំណុំរឿងបញ្ជូនទៅតុលាការ ។

មាត្រា ១៣.-

អាជ្ញាធរមានសមត្ថកិច្ច ត្រូវជួយផ្តល់អន្តរាគមន៍ ក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យ ក្នុងការបង្ក្រាបបទល្មើសពាក់ព័ន្ធនិងអនាម័យសត្តឃាតដ្ឋាន សត្វ សាច់ និង ផលិតផលសត្វ ក្នុងករណីមានការស្នើសុំពីភ្នាក់ងារបសុពេទ្យ ។



ជំពូកទី ៤
ឯកសណ្ឋាន និង សញ្ញាសម្គាល់ ភ្នាក់ងារបសុពេទ្យមានសមត្ថកិច្ច សម្លៀកបំពាក់អ្នកពិឃាតសត្វ និង អ្នកបំពេញការងារនៅសត្តឃាតដ្ឋាន

មាត្រា ១៤.-

ក្នុងពេលប្រតិបត្តិការត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋាន សត្វ សាច់ និង ផលិតផលសត្វ ភ្នាក់ងារបសុពេទ្យនៅសត្តឃាតដ្ឋាន និង ភ្នាក់ងារបសុពេទ្យដែលត្រូវបានចាត់តាំងឱ្យចុះត្រួតពិនិត្យ តាមកន្លែងតាំងលក់សាច់ និង ផលិតផលសត្វ ត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសម្គាល់ និង មានលិខិតបញ្ជាបេសកកម្មជាប់នឹងខ្លួន។

មាត្រា ១៥.-

អ្នកពិឃាតសត្វ និង អ្នកបំពេញការងារនៅក្នុងសត្តឃាតដ្ឋាន ត្រូវស្លៀកពាក់ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ដើម្បីធានាសុវត្ថិភាព និង រក្សាអនាម័យ តាមបទបញ្ជាផ្ទៃក្នុងរបស់សត្តឃាតដ្ឋាន។

ជំពូកទី ៥
ការប្រមូលកម្រៃសេវាកម្មត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ នៅសត្តឃាតដ្ឋាន

មាត្រា ១៦.-

ភ្នាក់ងារបសុពេទ្យដែលមានសមត្ថកិច្ចប្រចាំការនៅសត្តឃាតដ្ឋាន ត្រូវប្រមូលកម្រៃសេវាកម្មត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ ដើម្បីបង់ចូលថវិកាខេត្ត ក្រុង។

កម្រៃសេវាកម្មត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។

មាត្រា ១៧.-

នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល មានភារកិច្ចត្រួតពិនិត្យ ការអនុវត្តយកកម្រៃសេវាកម្មត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ របស់ការិយាល័យផលិតកម្ម និង បសុព្យាបាល នៃមន្ទីរកសិកម្ម ខេត្ត ក្រុង។

មាត្រា ១៨.-

រង្វាន់លើកទឹកចិត្តដល់មន្ត្រី ដែលបានចូលរួមបង្ក្រាបបទល្មើស ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ជំពូកទី ៦
ទោសប្បញ្ញត្តិ

មាត្រា ១៩.-

រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលប្រព្រឹត្តល្មើសនឹងមាត្រា ៧ នៃអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមមាត្រា ៦២ ជំពូកទី ៧ នៃច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និង សេវា ។

មាត្រា ២០.-

រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលប្រព្រឹត្តល្មើសនឹងមាត្រា ៨ និងមាត្រា ៩ នៃអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមមាត្រា ៦៣ ជំពូកទី ៧ នៃច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និង សេវា ។

ជំពូកទី ៧
អន្តរប្បញ្ញត្តិ

មាត្រា ២១.-

រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបានបង្កើតសត្តឃាតដ្ឋាន ឬ ធ្វើអាជីវកម្មពិឃាតសត្វនៅមុនពេលអនុក្រឹត្យនេះចូលជាធរមាន ក្រោមសុពលភាពនៃលិខិតអនុញ្ញាត ដែលបានផ្តល់ឱ្យដោយអនុលោមតាមអនុក្រឹត្យលេខ ២៩ អនក្រ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៩០ ឬ ដោយអនុលោមតាមលិខិតបទដ្ឋានណាផ្សេងក្តី ត្រូវបានអនុញ្ញាតឱ្យបន្តសុពលភាពក្នុងរយៈពេលមិនលើសពី ០៦ (ប្រាំមួយ) ខែ គិតចាប់ពីថ្ងៃអនុក្រឹត្យនេះចូលជាធរមាន ។ នៅក្នុងចិរវេលានេះ សាមីបុគ្គលនោះត្រូវបំពេញបែបបទសុំបង្កើតសត្តឃាតដ្ឋាន ឬ ការធ្វើអាជីវកម្មពិឃាតសត្វជាថ្មី ស្របតាមនីតិវិធី ដូចមានចែងក្នុងអនុក្រឹត្យនេះ ។

ជំពូកទី ៨

អវសានប្បញ្ញត្តិ

មាត្រា ២២.-

អនុក្រឹត្យលេខ ២៩ អនក្រ. ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៩០ ស្តីពីសត្តឃាតដ្ឋាន និង កន្លែងពិឃាតសត្វ និង បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ២៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែ សីហា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត ក្រុង
- ដូចមាត្រា ២៣
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៩៧ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការតម្លើងថ្នាក់ និងឋានន្តរសក្តិមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ស ម្រេ ច

មាត្រា ១.-

ត្រូវបានតម្លើងឋានន្តរសក្តិជូនមន្ត្រីរាជការ ពីឋានន្តរសក្តិអនុមន្ត្រី ទៅឋានន្តរសក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ដូចមានរាយនាមខាងក្រោម :

១	លោក **នួន ជីវ័ន្ត**	ពីអនុមន្ត្រីថ្នាក់លេខ៤	ទៅវរមន្ត្រីថ្នាក់លេខ **៦**
២	លោក **ស៊ួន សួន**	ពីអនុមន្ត្រីថ្នាក់លេខ **៥**	ទៅវរមន្ត្រីថ្នាក់លេខ **៧**

៣	លោកស្រី ស៊ី ចំនួនទុន្នី	ពីអនុមន្ត្រីថ្នាក់លេខ ៥	ទៅវរមន្ត្រីថ្នាក់លេខ ៧
៤	លោកស្រី យស់ ម៉ាណរាភា	ពីអនុមន្ត្រីថ្នាក់លេខ ៥	ទៅវរមន្ត្រីថ្នាក់លេខ ៧
៥	លោកស្រី រស់ ស៊ីម៉ារ៉ា	ពីអនុមន្ត្រីថ្នាក់លេខ៧	ទៅវរមន្ត្រីថ្នាក់លេខ ៨
៦	លោក នេត សេរី	ពីអនុមន្ត្រីថ្នាក់លេខ៨	ទៅវរមន្ត្រីថ្នាក់លេខ៩
៧	ឯកឧត្តម ហុង បញ្ញារិទ្ធ	ពីអនុមន្ត្រីថ្នាក់លេខ១០	ទៅវរមន្ត្រីថ្នាក់លេខ១០
៨	ឯកឧត្តម លុយ ដាវីត	ពីអនុមន្ត្រីថ្នាក់លេខ១១	ទៅវរមន្ត្រីថ្នាក់លេខ១០
៩	លោក ឡេង ចាន់ទីរៈ	ពីអនុមន្ត្រីថ្នាក់លេខ១០	ទៅវរមន្ត្រីថ្នាក់លេខ១០
១០	លោក យឹម សាលីន	ពីអនុមន្ត្រីថ្នាក់លេខ១១	ទៅវរមន្ត្រីថ្នាក់លេខ១០

មាត្រា ២.-

ត្រូវបានតម្លើងថ្នាក់ក្នុងឋានន្តរសក្តិវរមន្ត្រីជូនមន្ត្រីរាជការ នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ចាប់ពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៧ ដូចមានរាយនាមខាងក្រោម :

១១	លោក សុខ សោភ័ណ	ពីវរមន្ត្រីថ្នាក់លេខ ៤	ទៅវរមន្ត្រីថ្នាក់លេខ ៣
១២	លោក ណែ ម៉េងហ៊ាង	ពីវរមន្ត្រីថ្នាក់លេខ៧	ទៅវរមន្ត្រីថ្នាក់លេខ៦
១៣	លោកជំទាវ សឿង រដ្ឋចារី	ពីវរមន្ត្រីថ្នាក់លេខ៧	ទៅវរមន្ត្រីថ្នាក់លេខ៦
១៤	លោក ហោ មុន្នីរត្ន	ពីវរមន្ត្រីថ្នាក់លេខ៧	ទៅវរមន្ត្រីថ្នាក់លេខ៦

មាត្រា ៣.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ និងមាត្រា ២ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពី ថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ [illegible] ឆ្នាំ ២០០៧

[illegible] សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា "៤"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ៦៩៨ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា១: ត្រូវបានតែងតាំងមន្ត្រីចំនួន០២រូបជាជំនួយការឯកឧត្តម នាយឧត្តមសេនីយ៍ផ្កាយមាស៤ **គន់ គីម** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី ដូចមានរាយនាមខាងក្រោម

១-លោក **ឈា ស៊ីដារ៉ា** មានឋានៈស្មើ អគ្គនាយករង បន្ថែមលើមុខងារបច្ចុប្បន្ន

២-លោក **ចាប ម៉ុច** មានឋានៈស្មើ អគ្គនាយករង បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និង សាម៉ីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៦៩១ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការកែសម្រួលភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីការប្រែក្លាយសាលាភូមិន្ទនគរបាលទៅជាបណ្ឌិត្យសភានគរបាលកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានកែសំរួលភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១- លោកឧត្តមសេនីយ៍ឯក **ម៉ី ឈីដា** អត្តលេខ ០០៦៩ ពីនាយករងសាលាភូមិន្ទនគរបាល ទៅជាអនុប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា ។

២- លោកឧត្តមសេនីយ៍ទោ **ចំរុន ឫទ្ធី** អត្តលេខ ០០៣៣ ពីនាយករងសាលាភូមិន្ទនគរបាល ទៅជាអនុប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា ។

៣- លោកឧត្តមសេនីយ៍ទោ **ស ម៉ុឈីន** អត្តលេខ ២៣០៣ ពីនាយករងសាលាភូមិន្ទនគរបាល ទៅជាអនុប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា ។

៤- លោកឧត្តមសេនីយ៍ត្រី **សុខ ចំរើនរិទ្ធិ** អត្តលេខ ០៥៥២ ពីនាយករងសាលាភូមិន្ទនគរបាល ទៅជាអនុប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា ។

៥- លោកឧត្តមសេនីយ៍ត្រី **ឌន្ទូម ទី** អត្តលេខ ១១៨៨ ពីប្រធានមន្ទីរចាត់ការ នៃសាលាភូមិន្ទនគរបាល ទៅជាប្រធានមន្ទីរចាត់ការ នៃបណ្ឌិត្យសភានគរបាលកម្ពុជា ។

៦- លោកឧត្តមសេនីយ៍ត្រី **ម្រាក់ សំអាន** អត្តលេខ ០៣១៥ ពីប្រធានមជ្ឈមណ្ឌលបណ្តុះបណ្តាលបន្ត និងស្រាវជ្រាវ នៃសាលាភូមិន្ទនគរបាល ទៅជាទីប្រឹក្សាក្រសួងមហាផ្ទៃ ។

៧- លោកវរសេនីយ៍ឯក **ទេព ទុន្នី** អត្តលេខ ២៣០០ ពីអនុប្រធានមជ្ឈមណ្ឌលបណ្តុះបណ្តាលដំបូង នៃសាលាភូមិន្ទនគរបាល ទៅជានាយកវិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រនគរបាល នៃបណ្ឌិត្យសភានគរបាលកម្ពុជា ។

៨- លោកវរសេនីយ៍ឯក **សៅ ធីរៈឆ្លុយ** អត្តលេខ ០៥១៨ ពីអនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ទៅជានាយកវិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈនគរបាល នៃបណ្ឌិត្យសភានគរបាលកម្ពុជា ។

៩- លោកវរសេនីយ៍ឯក **ឈួន សុផេង** អត្តលេខ ៧៤៧៥ ពីអនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ទៅជានាយកវិទ្យាស្ថានគ្រប់គ្រង និងបញ្ជាដឹកនាំ នៃបណ្ឌិត្យសភានគរបាលកម្ពុជា ។

១០- លោកវរសេនីយ៍ឯក **ស្វាយ ចាន់ដា** អត្តលេខ ៣៤៦០ ពីអនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ទៅជានាយកវិទ្យាស្ថានពត៌មានវិទ្យា និងភាសាបរទេស នៃបណ្ឌិត្យសភានគរបាលកម្ពុជា ។

មាត្រា ២៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ៧ ឆ្នាំ ២០០៧

កន្លែងទទួល :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..៣៧០០..អនក្រ-បក

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងលោក តាំង សាមឿន ជាសមាជិកក្រុមលេខាសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ និងមាត្រា ២ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី[illegible]

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧០១ . អនក្រ . បក

អនុក្រឹត្យ

ស្ដីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេនព្រះភិក្ខុ **ពៅ សល់** ដែលមានសទ្ធាជ្រះថ្លានិងយកព្រះទ័យទុកដាក់កសាងវិស័យព្រះពុទ្ធសាសនា ព្រមទាំងសមិទ្ធផលនានាជាច្រើន នៅក្នុងវត្ត **ពោធិសត្វគីរីរម្យ** ស្ថិតក្នុងឃុំចំបក់ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ដោយបានចំណាយបច្ច័យអស់ចំនួន ២៧.០០០ ដុល្លារ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និងអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧០៤ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ អនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៩រូប ដែលបានបរិច្ចាគធនធានជួយកសាងសមិទ្ធផលសាធារណៈផ្សេង១ នៅស្រុកអង្គស្នួល ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមាសស្ថាបនាជាតិ :

១-ឯកឧត្តម **សែម សុវណ្ណានី** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ៤៤.០១០ ដុល្លារ
២-ព្រះតេជគុណ **ភួង ផល** ចៅអធិការវត្តដំណាក់អំពិលស្រុកអង្គស្នួល បច្ច័យចំនួន ២១៨.៧១៥ ដុល្លារ
៣-លោក **ល្មុយ ធឿម** សប្បុរសជននៅឃុំដំណាក់អំពិលស្រុកអង្គស្នួល ថវិកាចំនួន ៣៣.៦៩៩ ដុល្លារ
៤-លោក **ឡុង ទ៉ែត** សប្បុរសជននៅឃុំដំណាក់អំពិលស្រុកអង្គស្នួលថវិកាចំនួន២៨.០៨២.៥ ដុល្លារ
៥-លោក **ឃុំ ចំណាន** សប្បុរសជននៅឃុំដំណាក់អំពិលស្រុកអង្គស្នួលថវិកាចំនួន២៨.០៨២.៥ ដុល្លារ
៦-លោក **ស្លូ ទុទ្ធី** សប្បុរសជននៅឃុំដំណាក់អំពិលស្រុកអង្គស្នួល ថវិកាចំនួន ១១.២៣៣ ដុល្លារ
៧-លោក **លី វឌ្ឍនា** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១៥.៥១៨ ដុល្លារ
៨-លោក **គីម ផន** សប្បុរសជននៅឃុំដំណាក់អំពិលស្រុកអង្គស្នួល ថវិកាចំនួន ១១.២៣៣ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ :

-អ្នកស្រី **យិន សាយ** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ៤.៥១៨ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍនិវិស័យកសិកម្ម និងជនបទ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ សីហា ឆ្នាំ ២០០៧
នាយករដ្ឋមន្ត្រី
ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧០៣ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយសុវត្ថារា

ដោយ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អនុប្រធានក្រុមប្រឹក្សាស្តារ អភិវឌ្ឍនិវិស័យកសិកម្ម និងជនបទ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **អស្សឫទ្ធិ** ជូនលោក **ហេង វិជ្ជា** ប្រធាននាយកដ្ឋានស្ថិតិទិន្នន័យ សន្តិសុខស្បៀង និង អាហារូបត្ថម្ភ នៃក្រុមប្រឹក្សាស្តារអភិវឌ្ឍនិវិស័យកសិកម្ម និង ជនបទ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ និងប្រជាពលរដ្ឋ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍនិវិស័យកសិកម្ម និងជនបទ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ សីហា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧០៤ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

ដោយ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ អនុប្រធានក្រុមប្រឹក្សាស្តារ អភិវឌ្ឍនិស័យកសិកម្ម និងជនបទ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនមន្ត្រីរាជការ ចំនួន០៩រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិ និងប្រជាពលរដ្ឋ ដូចមានរាយនាមខាងក្រោម :-

១-លោក **ខឡូ សុខា** ប្រធានការិយាល័យស្ថិតិទិន្នន័យ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទីស្តីការគណៈរដ្ឋមន្ត្រី
២-លោក **អ៊ុម សារ៉ា** មន្ត្រីសាលាស្រុកអង្គស្នួល ខេត្តកណ្តាល
៣-លោក **ជួរ សុជាតិ** អភិបាលរងស្រុកអង្គស្នួល ខេត្តកណ្តាល
៤-លោក **ម៉ឹន គី** អភិបាលរងស្រុកអង្គស្នួល ខេត្តកណ្តាល
៥-លោក **ម៉េង ហ៊ិនលី** អភិបាលរងស្រុកអង្គស្នួល ខេត្តកណ្តាល
៦-លោក **នឹម នីរ៉ាដេត** អភិបាលរងស្រុកអង្គស្នួល ខេត្តកណ្តាល
៧-លោក **ឈិត ហេង** ប្រធានការិយាល័យសាធារណការនិងដឹកជញ្ជូន ស្រុកអង្គស្នួល ខេត្តកណ្តាល
៨-លោក **ឌិត្យ ខឡូ** អធិការនគរបាលស្រុកអង្គស្នួល ខេត្តកណ្តាល
៩-លោក **ម៉ុន មករា** មន្ត្រីនាយកដ្ឋានផែនការ និងសហប្រតិបត្តិការអន្តរជាតិ ទីស្តីការគណៈរដ្ឋមន្ត្រី

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍនិស័យកសិកម្ម និងជនបទ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ សីហា ឆ្នាំ ២០០៧
នាយករដ្ឋមន្ត្រី
ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ...៧០៥...អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
រាជ
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ អភិបាលខេត្តកណ្តាល

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនសប្បុរសជន ចំនួន២៧រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងសមិទ្ធផលនានា ក្នុងវត្តមុនីសុវណ្ណ ហៅ វត្តចំពុះក្អែក ស្ថិតក្នុងឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម :-

១-ឯកឧត្តម គង់ ទ្រីវ
២-លោកជំទាវ អ៊ុក ម៉ាលី
៣-លោកជំទាវ លឹម ឈីវហួរ
៤-លោកជំទាវ សុគ័ន្ធ ថាវី
៥-លោកជំទាវ ហូ ឈួន
៦-ឯកឧត្តម ឆៀ វិញ
៧-លោកជំទាវ គី សុន្ធា យុន ទុធ
៨-លោកជំទាវ លឹម ស្រីពៅ
៩-ឧកញ៉ា ផៃ ហុកឈួន
១០-ឯកឧត្តម ទាំ ឈូដា
១១-ឯកឧត្តម ឡុង ម៉េង
១២-ឧកញ៉ា អ៊ូ ឆាយ
១៣-ឧកញ៉ា ហ៊ីង គីមហេង
១៤-ឧកញ៉ា ស៊ុត តារា
១៥- ឧកញ៉ា គីម សេង
១៦- ឧបាសក លឹម ឈុន
